ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ថ្ងៃ.អង្គារ.ទី.១៤.កើត.ខែ.ពិដ្ឋ.ឆ្នាំ.ច.សំរឹទ្ធិស័ក.ព.ស.២៥៦២

លេខ ៥៤១៦ សរ.កស

រាជធានីភ្នំពេញ ថ្ងៃទី..១២.. ខែ.មិថុនា. ឆ្នាំ២០១៨

សេចក្តីជូនដំណឹង
ស្តីពី
ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជូនដំណឹងដល់ ឯកឧត្តម លោក លោកស្រីប្រធានគ្រប់អង្គភាព ក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងលោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ជ្រាបថា យោងអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និង នីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ សារាចរលេខ ០៧.សរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ របស់រាជរដ្ឋាភិបាលស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងយោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងគោលបំណងពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋឱ្យមានគណនេយ្យភាព ប្រសិទ្ធភាព តម្លាភាព និងស័ក្តិសិទ្ធភាព ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រេចចាត់តាំងក្រុមការងារអធិការកិច្ចដឹកនាំដោយ **ឯកឧត្តម គីម សុន អគ្គាធិការ** នៃអគ្គាធិការដ្ឋាន និងមន្ត្រីជំនាញអធិការកិច្ច ដើម្បីចុះត្រួតពិនិត្យ លើការអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ របស់អង្គភាពក្រោមឱវាទក្រសួងទាំងអស់ចាប់ពីខែសីហា ឆ្នាំ២០១៨ នេះតទៅ។

ទទួលបានសេចក្តីជូនដំណឹងនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ត្រូវចូលរួមអនុវត្តន៍ឱ្យមានប្រសិទ្ធភាពដោយស្មារតីទទួលខុសត្រូវខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

វេង សាខុន

កន្លែងទទួល:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chomkarmon Phnom penh, Cambodia.
ទូរស័ព្ទលេខ:(០២៣) ៧២៦ ១២៨/៧២៦ ១២៩ ទូរសារលេខ:(៨៥៥) ២៣-២១៧ ៣២០
Phone:(023) 726 128/726 129 Fax:(855) 23-217 320